**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

## ជូនចំពោះ
## ឯកឧត្តម ហាស់ ប៊ុនថូន
## អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង ក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីក្តុកក្តួលរន្ធត់ចិត្តយ៉ាងខ្លាំង ដោយបានទទួលដំណឹងថា ឧបាសក **ហាស់ ថុន** ដែលត្រូវជាឪពុកបង្កើតរបស់ឯកឧត្តម **ហាស់ ប៊ុនថូន** អគ្គនាយក នៃអគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ បានទទួលមរណភាពនៅថ្ងៃអង្គារ ១៤កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង**២:០០**នាទីរំលងអធ្រាត ក្នុងជន្មាយុ**៨០**ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្តនិងសមានចិត្តដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងនូវមរណទុក្ខដ៏ជ្រាលជ្រៅ ពោរពេញដោយក្តីសោកស្តាយជាអនេកប្បការជូនចំពោះឧបាសក **ហាស់ ថុន** ដែលបានធ្វើមរណកាលលាចាកលោក លាចាកពីបុត្រធីតា និងក្រុមញាតិគ្រួសារជាទីស្រលាញ់។

ខ្ញុំសូមឧទ្ទិសបបួងសួងជូនវិញ្ញាណក្ខន្ធឧបាសក **ហាស់ ថុន** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម និងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃអង្គារ ១៤កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**